# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**KINGDOM OF CAMBODIA**
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
**Ministry of Commerce**
No. ១១១ MOC / SM 2006

## ប្រកាស
### ស្តីពីវិធានការចាំបាច់មួយចំនួនសំរាប់គ្រប់គ្រងការនាំចេញ
### ក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី .
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម .
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម .
- យោងតាមការចាំបាច់របស់ក្រសួង ។

## សំរេច

**ប្រការ ១ :** រាល់អ្នកនាំចេញទំនិញក្រោមប្រព័ន្ធ MFN និង GSP ចាំបាច់ត្រូវមកបំពេញបែបបទស្នើសុំវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ (C/O) និង បំពេញកាតព្វកិច្ចបង់កំរៃគ្រប់គ្រងការនាំចេញ EMF (Export Management Fee) ក្នុងរយៈពេល ៣០ ថ្ងៃបន្ទាប់ពីទំនិញត្រូវបាននាំចេញរួចហើយ ។

**ប្រការ ២ :** កាលបរិច្ឆេទត្រួតពិនិត្យទំនិញរបស់មន្ត្រីគយ និង កាំកុងត្រូលដែលបានបញ្ជាក់នៅលើកំណត់ហេតុរួមស្តីពីការត្រួតពិនិត្យទំនិញ នឹងត្រូវបានកំណត់យកជាកាលបរិច្ឆេទនៃការចេញទំនិញ ។

**ប្រការ ៣ :** អ្នកនាំចេញទំនិញសំលៀកបំពាក់ក្នុងឈុតជាមួយគ្នាដែលស្ថិតក្នុងប្រភេទពីរផ្សេងគ្នា (Two Different Categories) ត្រូវបំពេញកាតព្វកិច្ចបង់ EMF ពាក់កណ្តាលថ្លៃក្នុងប្រភេទ (Category) នីមួយៗ ។

**ប្រការ ៤ :** ក្នុងករណីមិនយកចិត្តទុកដាក់ យឺតយូរក្នុងការស្នើសុំ C/O និងបង់ EMF លើសពីកាលបរិច្ឆេទកំណត់ក្នុងប្រការ ១ អ្នកនាំចេញត្រូវទទួលរងពិន័យ ១% (មួយភាគរយ) ក្នុងមួយថ្ងៃលើតំលៃ EMF ដែលត្រូវបង់ ។

Ministry of Commerce
20 A & B Preah Norodom Boulevard
Phnom Penh 12205.
Kingdom of Cambodia

Senior Minister's Cabinet
Tel: (855) 23 427 358/214 946
Fax: (855) 23-213-288/991-708
E-mail: moccabdir@yahoo.com

**ប្រការ ៥ :** អ្នកនាំចេញត្រូវទទួលធ្វើអធិការកិច្ចផលិតកម្មមួយខែមួយលើកគត់ ដើម្បីផ្ទៀងផ្ទាត់បទដ្ឋាន និង កាត់ស្តុកការចំណាយវត្ថុធាតុដើមតាម C/O នីមួយៗដែលក្រសួងបានចេញជូន ដោយមិនអនុញ្ញាតអោយការងារផ្ទៀងផ្ទាត់បទដ្ឋាន និងកាត់ស្តុកនេះនៅជំពាក់ឆ្លងខែដែលនាំដល់ការច្របូកច្របល់ក្នុងការគ្រប់គ្រងសន្និធិ និងការអនុវត្តន៍វិធានប្រភពដើមរបស់ប្រទេសដែលផ្តល់ភាពអនុគ្រោះពាណិជ្ជកម្មចំពោះកម្ពុជា ។

**ប្រការ ៦ :** ការអនុវត្តន៍កិច្ចសន្យាជួលផលិតត្រូវបានអនុញ្ញាតជូនអ្នកនាំចេញទាំងអស់ ដោយជួលអ្នកទទួលផលិតដែលមានច្បាប់អនុញ្ញាតត្រឹមត្រូវ និង គោរពច្បាប់ការងាររបស់ព្រះរាជាណាចក្រកម្ពុជា ។ រាល់លើកដែលធ្វើកិច្ចសន្យាជួលផលិត ត្រូវជូនដំណឹងមកនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មទៅតាមគំរូណែនាំដែលបានកំណត់ ។

**ប្រការ ៧ :** ករណីអ្នកនាំចេញមិនយកចិត្តទុកដាក់បំពេញកាតព្វកិច្ចក្នុងប្រការ ៥ និង ប្រការ ៦ ខាងលើ ក្រសួងពាណិជ្ជកម្មនឹងផ្អាកការផ្តល់ C/O ជូនរហូតដល់ការខ្វះខាតដែលកើតមានក្នុងប្រការទាំង ២ ត្រូវបានបំពេញគ្រប់ជ្រុងជ្រោយ ។

**ប្រការ ៨ :** សេចក្តីប្រកាស និង លិខិតជូនដំណឹងទាំងឡាយដែលមានខ្លឹមសារផ្ទុយពីនេះ នឹងត្រូវទុកជានិរាករណ៍ ។

**ប្រការ ៩ :** នាយិកាខុទ្ទកាល័យ អគ្គនាយកបច្ចេកទេស អគ្គនាយករដ្ឋបាលហិរញ្ញវត្ថុ អគ្គាធិការ ប្រធាននាយកដ្ឋានកាំកុងត្រូល ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ប្រធាននាយកដ្ឋានអាស៊ាន និង អង្គការអន្តរជាតិ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានគណនេយ្យ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះអោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៦ តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ [illegible] ឆ្នាំ ២០០៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម_ប្រសិទ្ធ**

**ចម្លងជូន :**

- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- ទីចាត់ការគយ និង រដ្ឋាករ
- សមាគមកាត់ដេរសំលៀកបំពាក់នៅកម្ពុជា
- រោងចក្រកាត់ដេរសំលៀកបំពាក់នៅកម្ពុជា " ដើម្បីសហការអនុវត្តន៍ "
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



Ministry of Commerce
20 A & B Preah Norodom Boulevard
Phnom Penh 12205
Kingdom of Cambodia

Senior Minister's Cabinet
Tel: (855) 23 427 358/214 946
Fax: (855) 23-213-288/991-708
E-mail: moccabdir@yahoo.com